**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៣០/០៥/២០១១ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១១

**ជម្រាបមក**

**លោក ហ៊ីង យឿន**

ទីលំនៅបច្ចុប្បន្នផ្ទះលេខ ៦៩ AE3 ផ្លូវលេខ ១៧៨ ភូមិ៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ជាតំណាងលោក **ចេវ ហៃ** អ្នកសង្កេតការណ៍តំណាងគណបក្ស សម រង្ស៊ី

**__កម្មវត្ថុ__**: រឿងទាក់ទងនឹងពាក្យបណ្ដឹងបដិសេធសេចក្ដីសម្រេចលិខិតលេខ ៥០៤/១១ គ.ជ.ប ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយទាមទារឱ្យផ្ដន្ទាទោសលោក **ជៀម ខូយ** ប្រធានក្រុមប្រឹក្សា និង សមាជិកក្រុមប្រឹក្សាសង្កាត់តាខ្មៅចំនួន ៦រូបទៀតពីខាងគណបក្សប្រជាជនកម្ពុជា

**__យោង__** : ពាក្យបណ្ដឹងរបស់លោក លេខ ១២៨/១១ គ.ស.រ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបលោកថា ក្នុងកិច្ចប្រជុំនាថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើពាក្យបណ្ដឹងរបស់លោក រួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា តាមមាត្រា ២៦ និង មាត្រា ២៧ ថ្មី នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្ដឹងរបស់លោកមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**